# ពុទ្ធសាសនានិងតម្លៃសីលធម៌ចំពោះស្វាមីភរិយា

សុភមង្គលនៃជីវិតគូស្វាមីភរិយា តាមទស្សនៈពុទ្ធសាសនា គឺស្ថិតនៅលើសេចក្តីសុខនៅក្នុងគ្រួសាររបស់ខ្លួន ដែលហៅថា សុខកាយ សប្បាយចិត្ត ។ សុខកាយ គឺការដែលមិនមានជម្ងឺតម្កាត់ផ្សេងៗ រាងកាយរឹងមាំ អវៈយវៈ ទាំងអស់មានសុខភាពមាំមួន ធ្វើការងារបានគ្រប់យ៉ាងទាំងអស់។ សុខកាយម្យ៉ាងទៀតគឺការដែល មានបច្ច័យ៤គ្រប់គ្រាន់ គឺមានម្ហូបអាហារត្រឹមត្រូវតាមក្បួនអនាម័យ មានសំលៀកបំពាក់ មានផ្ទះសំបែងនិង មានថ្នាំសំរាប់ ព្យាបាលជម្ងឺ។ សេចក្តីសុខខាងកាយនេះ ជាសេចក្តីសុខដែលគេស្គាល់គ្រប់គ្នាហើយដែលគ្រួសារនីមួយៗតែងប្រាថ្នា។ តែសេចក្តីសុខប្រភេទនេះមិនទាន់គ្រប់គ្រាន់ទៅនឹងសេចក្តីត្រូវការរបស់សុភមង្គលទេ ។ ហេតុបានជាដូច្នេះព្រោះថាបើគ្រួសារ(ស្វាមីភរិយា)នោះមានបច្ច័យ ៤ គ្រប់គ្រាន់មែនតែអ្នកជាមនុស្សដែលខ្វះសីលធម៌ខ្វះការកក់ក្តៅក្នុងក្រុមគ្រួសារ ប្តីប្រពន្ធកូនប្រព្រឹត្តតែអំពើអបាយមុខដែលលោកហៅថា ឆ្កួតស្រា ឆ្កួតស្រី ឆ្កួតល្បែងពាលា... នោះជីវិតស្វាមីភរិយានឹងមិនមានសេចក្តីសុខឡើយ។

អ្នកមានទ្រព្យច្រើន តែជួនកាលអ្នកមិនមានសេចក្តីសុខ ដេកលក់ស្រួលស្មើនឹងជីវិតគូស្វាមីភរិយាខ្លះដែលក្រទ្រព្យសម្បត្តិ តែចេះស្រលាញ់គ្នាល្អកល្អឺន រស់នៅជាមួយគ្នាក្នុងសុខដុមភាពឡើយ។ ដូច្នេះសេចក្តីសុខខាងផ្លូវចិត្តទើបជាសេចក្តីសុខដែលសំរាប់បន្ថែមទៅលើសេចក្តីសុខខាងផ្លូវកាយ ដើម្បីឲ្យសុភមង្គលខាងជីវិតគូស្វាមី ភរិយាមានតុល្យភាព។

អត្ថបទតទៅនេះ គឺជាកម្រងទស្សនៈពុទ្ធសាសនា ដែលបានដកស្រង់យកអន្លើខ្លះពីគម្ពីរទីឃនិកាយ សុត្តន្តបិដក អន្លើខ្លះទៀតពីសៀវភៅ «ជីវិតអពាហ៍ពិពាហ៍» របស់លោកធម្មបណ្ឌិត ហេងមណីចិន្តានិងពីច្បាប់ផ្សេងៗមករៀបរៀង និងពន្យល់សេចក្តីទុកជាគតិណើរលើវិថីជីវិតដែលសែនលំបាក។ តម្លៃសីលធម៌ចំពោះស្វាមីភរិយា មានអ្វីខ្លះដែលគួរសិក្សានិងអនុវត្ត?

## I. <u>នាទី និងសីលធម៌ស្វាមី ចំពោះភរិយា</u>

ភរិយា,តាមអត្ថន័យ, គឺស្ត្រីដែលស្វាមីត្រូវចិញ្ចឹម, ត្រូវអនុគ្រោះ។ ការអនុគ្រោះរបស់ស្វាមីចំពោះភរិយា លោកបានចែកធម្មៈ ៥ប្រការ សំរាប់អនុវត្តគឺ:

១. ស្រលាញ់ភរិយាដ៏ស្មោះ ដោយប្រើសំដីទន់ភ្លន់ ផ្អែមល្ហែមទៅកាន់ភរិយា, មិនប្រើពាក្យសំដីគ្រោតគ្រាតទៅកាន់ភរិយា។

២. មិនបៀតបៀន, មិនមើលងាយមើលថោកភរិយា ។

៣. មិនប្រព្រឹត្តកន្លងចិត្តភរិយា (មិនក្បត់ភរិយា) ។

៤. ប្រគល់កិច្ចការសព្វយ៉ាងនៅក្នុងផ្ទះ អោយទៅភរិយាកាន់កាប់។

៥. ផ្គត់ផ្គង់សំលៀកបំពាក់ គ្រឿងអលង្ការសមគួរដល់ភរិយា។

ស្វាមីក៏ត្រូវយល់ដឹងនិងជួយរំលែកសេចក្តីទុក្ខសំបាករបស់ភរិយា ក្នុងឋានៈជាស្រីនិងជាភេទទន់ខ្សោយ គឺៈ ទុក្ខខាងផ្លូវកាយនិងផ្លូវចិត្ត នៅពេលមានគភ៌មិនអាចប្រើឥរិយាបទទាំង៤ (ដេក ដើរ ឈរ អង្គុយ) និងប្រកបកិច្ច ការបានស្រួល, ទុក្ខនៅពេល ឆ្លងទន្លេប្រសូតបុត្រ...។

**II. នាទី និងសីលធមិភរិយា ចំពោះស្វាមី**

*.ក) ក្នុងឋានៈជាភរិយា*

គប្បីយល់ដឹងសីលធម៌ ៥ ប្រការ សំរាប់អនុវត្តចំពោះស្វាមីខ្លួន គឺៈ

១. ចាត់ចែងការងារក្នុងផ្ទះ មានបាយទឹកជាដើមដោយផ្ចិតផ្ចង់, មើលរៀបចំឥវ៉ាន់ ទ្រព្យសម្បត្តិ រៀបចំផ្ទះសំបែងឲ្យមានសណ្តាប់ធ្នាប់ រៀបរយ ស្អាតបាត មានអនាម័យ ដូចសុភាសិត ថា «*ដំណេកដេកជាខ្នាត អោយសំអាតសំអាងជា ទើបទេវតារក្សា ចំរើនសុខស្រីសួស្តី*» ។

២. សង្គ្រោះញាតិខាងស្វាមីនិងញាតិខាងខ្លួនឲ្យបានស្មើមុខគ្នា រួមទាំងបដិសណ្ឋារកិច្ចចំពោះបុគ្គលដែលស្វាមីរាប់អាន ពេលដែលជននោះមកដល់ផ្ទះ។

៣.ថែទាំទុកដាក់ទ្រព្យសម្បត្តិដែលស្វាមីរកបានមក, របស់បាត់ត្រូវតាមរក, របស់ចាស់ត្រូវជួសជុលប្រើ, និងត្រូវចេះប្រមាណក្នុងការប្រើទ្រព្យសម្បត្តិ ។

ត្រង់នាទី ទី៣ នេះ នារីជាភរិយាត្រូវចងចាំពាក្យបុរាណថាៈ

*« ប្តីជាអ្នករក ទ្រព្យធនបានមក ប្រពន្ធទុកដាក់ចាស់ទុំបូរាណ បានពោលបញ្ជាក់ អោយនាងអោយអ្នក ចងចាំគ្រប់ប្រាណ។ សំណាបយោងដី រីឯស្រីៗ យោងប្រុសសាមាន្យ(សាមញ្ញ) ទោះមារយាទខ្សោយ ក៏ដោយបើបាន ស្រីមានសន្តាន ខ្ជាប់ខ្ជួនមួនមាំ ។ តែងបានចំរើនទ្រព្យាកើតកើន ព្រោះស្រីថែទាំ ចាត់ចែងទុកដាក់ ចេះលាក់សន្សំ សង្វាតខិតខំ រក្សាឲ្យគង់ » ។ « ខ្លែងហើរដ្បិតខ្យល់ នាយថ្កើងដ្បិតពល រក្សាឲ្យសុខ ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុកដ្បិតភរិយាជា »* ។

៤. មិនប្រព្រឹត្តកន្លងចិត្តស្វាមី ( មិនក្បត់ចិត្តស្វាមី ) ។

៥. ឈ្លាសវៃ ប៉ិនប្រសប់ និងប្រឹងប្រែងជានិច្ចក្នុងកិច្ចការគ្រប់យ៉ាង ព្រោះខ្លួនមាននាទីជា « *មេផ្ទះ, មេកិច្ចការជាធំក្នុងគ្រួសារ*» ។

.ខ) របៀបរស់នៅរបស់ស្ត្រី *(១)*

*នារីពេលមានស្វាមីគប្បីចងចាំគឺ:*

១) ភ្លើងក្នុងកុំនាំចេញក្រៅ,

២) ភ្លើងក្រៅកុំនាំចូលក្នុង,

៣) ត្រូវអោយបុគ្គលដែលអោយ,

៤) មិនត្រូវអោយដល់បុគ្គលដែលមិនអោយ,

៥) ត្រូវអោយដល់បុគ្គលដែលអោយក្តីមិនអោយក្តី,

៦) ត្រូវអង្គុយដោយស្រួលបួល,

៧) ត្រូវបរិភោគដោយស្រួលបួល,

៨) ត្រូវដេកដោយស្រួលបួល,

៩) ត្រូវបូជាភ្លើង ឬបំរើភ្លើង,

១០) ត្រូវថ្វាយបង្គំទេវតាក្នុងផ្ទះ ។

*សេចក្តីពន្យល់:*

១) *ភ្លើងក្នុងកុំនាំចេញក្រៅ* ។ មានន័យថា រឿងរ៉ាវណាដែលសៅហ្មងក្តៅក្រហាយ មិនល្អ អាក្រក់ ដែលជារឿង ផ្ទៃក្នុងរបស់ក្រុមគ្រួសារខ្លួន, មាតាបិតាខ្លួនមិនត្រូវនាំចេញទៅផ្សាយ ដើរប្រាប់គេ ប្រាប់ឯង ដោយហោចទៅសូម្បី តែសាច់ញាតិខ្លួនឡើយ។

២) *ភ្លើងក្រៅកុំនាំចូលក្នុង* ។ មានន័យថា រឿងណាដែលមិនល្អ មិនមានប្រយោជនិជារឿងក្តៅក្រហាយ ហើយមិនទាក់ទងនឹងសាច់រឿងរបស់ខ្លួនទេ មិនគប្បីនាំចូលមកក្នុងផ្ទះអោយក្រុមគ្រួសារបានទទួលការក្តៅក្រហាយផងដែរនោះទេ។ ទោះជារឿងក្តៅក្រហាយនោះទាក់ទងទៅ

នឹងកេរ្តិ៍ឈ្មោះ និងផលប្រយោជន៍របស់គ្រួសារឬស្វាមីខ្លួនក្តី ក៏ត្រូវរកឱកាសនិយាយដែរដើម្បីកុំឲ្យក្តៅទាំងរឿងក្តៅទាំងមនុស្សទៀត ។ មានភរិយាខ្លះ ឃើញស្វាមីមកពី ធ្វើការហត់នឿយ ឬមានរឿងមុខមិនស្រួលមកដល់ផ្ទះ មិនទាន់ទាំងដាក់គូថអង្គុយផង ក៏ស្រាប់តែនាំយករឿងអាក្រក់រឿងក្តៅក្រហាយទៅពិតទូលបញ្ឆេះធ្វើឲ្យស្វាមីដែលកំពុងស្រួលៗនោះ ក្តៅក្រហាយ ឆេះភ្លាមមួយរំពេច ។ ប្រការនេះនាងជាភរិយាគួរយល់ដឹង ។

៣) *ត្រូវអោយបុគ្គលដែលអោយ*។ មានអ្នកមកខ្ចីទ្រព្យបើជឿទុកចិត្តថានឹងសងវិញសឹមអោយខ្ចី ។

៤) *មិនត្រូវអោយដល់បុគ្គលដែលមិនអោយ*។ បើមានអ្នកមកខ្ចីទ្រព្យនោះ មិនគួរទុកចិត្តថាសងវិញទេមិនត្រូវអោយខ្ចីទេ ។ បើអោយខ្ចីត្រូវគិតថា របស់នោះទុកដូចជាបោះចោលទៅក្នុងទឹកទន្លេ ។

៥) *ត្រូវអោយដល់បុគ្គលដែលអោយក្តីមិនអោយក្តី* ។ ត្រូវតែអោយដោយសង្ឃឹមថាសងវិញឬមិនសងវិញដូច ជាបងប្អូនដែលយើងត្រូវតែជួយដោះទុក្ខធុរៈ មួយទៀតបានដល់ការដាក់ទាន ដល់ស្មូមយាចក រួមទាំងការធ្វើបុណ្យ ទាន ដែលត្រូវធ្វើជា ប្រពៃណី របស់យើង ។

៦) *ត្រូវអង្គុយដោយស្រួលបួល* ។ ត្រូវអង្គុយដឹងខ្ពស់ដឹងទាប, អង្គុយប្រយ័ត្នប្រយែង មិនច្រដេងច្រដាង យះដៃយះជើង... ។

៧) *ត្រូវបរិភោគដោយស្រួលបួល* ។ ត្រូវមានសុជីវធម៌ក្នុងការបរិភោគអាហារ គឺបរិភោគអោយដឹងមុនក្រោយ បរិភោគជាមួយអ្នកណា ពេលណាគួរបរិភោគ...។

៨) *ត្រូវដេកដោយស្រួលបួល* ។ គឺការរៀបចំដំណេកអោយបានសមរម្យស្រួលបួល រួមទាំងការត្រៀមវត្ថុចាំបាច់ខ្លះពេលចូលដេកកុំឲ្យពិបាកងើបដើរឆ្ងាយទៅយក ។ ទំនៀមខ្មែរពីដើមមុនដេកភរិយាត្រូវមូរបារី អប់ទឹកផ្តិលដាក់ចុងជើង ។ ក្នុងរឿងសិរី ៣ ប្រការ របស់ធម្មបាលមាណពដែលដោះប្រស្នាជាមួយកបិលមហាព្រហ្ម បានអធិប្បាយថា: ពេលព្រឹកសិរីនៅមុខ ដូច្នេះត្រូវលុបមុខ, ពេលថ្ងៃសិរីនៅទ្រូង ត្រូវលាបស្រឡាបដើមទ្រូង, ពេលល្ងាចសិរីនៅជើង ត្រូវលាងជើងមុនពេលចូលដេក ។ ម្យ៉ាងទៀត:

= មិនត្រូវកន្លងជើងប្តីឬខ្លួនប្តី ព្រោះខ្មែរប្រកាន់ថា ប្រុសៗមានគ្រូបាធ្យាយកំណើតកាន់ឬបើប្តីជាអ្នករៀនមន្តអាគមក៏នឹងសាបអស់។

= ត្រូវដេកនៅខាងឆ្វេងស្វាមី ឯក្បាលដំណេក គួរដាក់នៅទិសខាងត្បូង ព្រោះ « ត្បូង » ប្រែថា«ក្បាល» ។

= គួរមើលឲ្យបានច្បាស់ពេលដេក មិនត្រូវបែរជើងទៅរកស្វាមី មាតាបិតា ឬព្រះពុទ្ធរូបទេ ព្រោះដូច ជាយើង យកជើង ទៅធាក់លោកអញ្ចឹង ។

= ត្រូវដេកប្រយ័ត្នប្រយែងក្រែងលេចកេរ្តិ៍ខ្មាស់ ឬពេលងើបពីដេករបូតសំពត់ជាដើម ។ ខ្មែរមានទំនៀមថា « ប្រពន្ធត្រូវដេកក្រោយប្ដី និងភ្ញាក់មុនប្ដី » ព្រោះលោកយល់ថា ប្ដីធ្វើការនឿយហត់ពីថ្ងៃហើយឯប្រពន្ធនៅផ្ទះ ដូច្នេះត្រូវមើលខុសត្រូវ រៀបចំទុកដាក់ចានក្បានឲ្យហើយ, មើលទ្វារបង្អួចក្រែងបិទមិនជិត, មើលភ្លើងក្រែងរាលឆេះ ។ល។ លុះភ្ញាក់ត្រូវភ្ញាក់មុន ព្រោះម្យ៉ាងដើម្បីកុំឲ្យឃើញសភាពមិនរៀបរយរបស់សំពត់ខោអាវពេលដេក និងរៀបចំអាហារពេលព្រឹកសំរាប់ស្វាមីផងព្រមទាំងបោសច្រាសផ្ទះសំបែងឲ្យបានស្អាតបាតស្រេចបាច់ហើយ ម្យ៉ាងទៀត ក៏មិនគប្បីដេកកណ្ដាលវាលដែរ ត្រូវមានអ្វីបិទបាំងឬជាទីកំបាំងភ្នែកអ្នកផង ។

៩) *ត្រូវបូជាភ្លើងឬបំរើភ្លើង* ។ ក្នុងទីនេះបានដល់ស្វាមីដែលភរិយាត្រូវគោរពបំរើ ប្រណិប័តន៍ថ្នាក់ថ្នមរួមទាំងការ បំពេញសេចក្ដីត្រូវការខាងភេទផងដែរ ។ ភ្លើងនេះបើយើងបូជា ឬបំរើមិនល្អ វានឹងអាចរលាក ឬឆេះដល់នាងជា ភរិយាពិតប្រាកដ ។

១០) *ត្រូវថ្វាយបង្គំទេវតាក្នុងផ្ទះ*។ ទេវតាក្នុងផ្ទះនេះ បានដល់មាតាបិតារបស់ខ្លួនក្ដី របស់ស្វាមីក្ដីដែលយើងនៅជាមួយ, និងមួយទៀត បានដល់គ្រឿងសក្ការបូជាក្នុងផ្ទះដែលយើងជឿគោរពបូជា ។ ការបំរើមាតាបិតា ការគោរព ប្រណិប័តន៍លោក ថ្វាយបង្គំលោក រមែងបាននូវអានិសង្សនិងសេចក្ដីសុខជាពន់ប្រមាណ ព្រោះព្រះសម្មាសម្ពុទ្ធលោកបានមានពុទ្ធដីកាថា: *មាតាបិតាជាព្រះព្រហ្មរបស់កូនផង ជាទេវតាដើមផង ជាគ្រូផង និងជាអហុនេយ្យបុគ្គលរបស់កូនផង កូនណាគោរពបូជាបុណ្យរមែងកើតដល់កូនប្រុសស្រីនោះមិនដាច់ ។*

ក្រៅពីឱវាទទាំង១០នេះ នៅមានឱវាទផ្សេងៗទៀតជាច្រើន ដែលសុទ្ធសឹងជាពាក្យទូន្មានចំពោះស្ត្រីដែលនឹងត្រូវមានស្វាមី។ ជាពិសេសនៅក្នុងរឿងវិធុរបណ្ឌិតជាតក នៅពេលដែលនាងវិមលាដែលជាមហេសីស្ដេចនាគផ្ដាំដល់បុត្រី គឺនាងឥរន្ទវតី មុននឹងធ្វើដំណើរទៅជាមួយស្វាមីគឺបុណ្ណកយក្ស។ អ្នកប្រាជ្ញបណ្ឌិតយើង បានរៀបរៀងតែងពាក្យកាព្យឡើង ឈ្មោះថា«ច្បាប់ស្រី» មានលំនាំជាបទភុជង្គលីលា ដែលខ្មែរយើងនិយមអោយកូនស្រីទន្ទេញណាស់ ។

ដំណើររួមរស់នៃស្វាមីភរិយា មិនមែនសំរាប់តែសេចក្ដីសុខស្រួលទាំងផ្លូវកាយទាំងផ្លូវចិត្តនៅក្នុងផ្ទះមួយជាមួយគ្នាប៉ុណ្ណោះទេ។ គូស្វាមីភរិយា ត្រូវចេះឆ្លៀតទាញយកប្រយោជន៍អំពីភាពស្និទ្ធស្នាលនៃការរួមរស់ជាមួយគ្នានេះជួយណែនាំ រំលឹកដាស់តឿនគ្នាឲ្យបណ្ដុះចិត្តគំនិតមានជំនឿក្នុង ព្រះពុទ្ធសាសនា , ឲ្យចេះប្រយ័ត្ន មិនបណ្ដោយឲ្យធ្លាក់លង់ទៅក្នុងអបាយមុខណាមួយមាន ស្រី ស្រា ល្បែងភ្នាល់ ការសេពគប់រកមនុស្សអាក្រក់ជាមិត្តជាដើមដែលជាហេតុ នាំឲ្យវិនាសទាំងទ្រព្យ ទាំងខ្លួនប្រាណ ។

មានស្វាមីភរិយាចំណាស់មួយគូ ដែលជាប់ឈ្មោះថាជាស្វាមីភរិយាឧត្តមបានទៅថ្វាយបង្គំព្រះពុទ្ធ ហើយទូលសួរថា: បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំព្រះករុណាបានគ្នាជាប្ដីប្រពន្ធ ក្រោយពេលដែលបានស្គាល់គ្នាតាំងពីនៅក្មេងៗដូចគ្នា ហើយយើងខ្ញុំស្គាល់តែសេចក្ដីសុខពុំដែលមានរឿងហេតុមោះហ្មងអ្វីនឹងគ្នាម្ដងណាទេ។ សូមព្រះអង្គមេត្តាពន្យល់ប្រាប់យើងខ្ញុំផង ថាតើយើងខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីអាចនឹងបានជួបគ្នាទៀតនៅជាតិក្រោយ ។

ព្រះពុទ្ធទ្រង់ត្រាស់តបប្រកបដោយគតិបណ្ឌិតថា:
បើអ្នកទាំងពីរមានជំនឿសាសនាដូចគ្នាបេះបិទ(សមសទ្ធា),
បើអ្នកទាំងពីរទទួលយកសេចក្ដីទូន្មានព្រះសាសនាតាមរបៀបដូចគ្នាបេះបិទ(សមសីលា),
បើអ្នកទាំងពីរសាងកុសលទានដូចគ្នា(សមចាគា),
បើអ្នកទាំងពីរមានការសិក្សាអប់រំ និងវៃឆ្លាតប្រហាក់ប្រហែលគ្នា (សមបញ្ញា)...
ទៅជាតិក្រោយទៀត អ្នកទាំងពីរនឹងបានប្រកបដោយចិត្តដូចគ្នាទៀត ពោលគឺ នឹងអាចជួបគ្នាគ្រប់ៗជាតិជាមិនខាន។

*ដកស្រង់រៀបរៀងនិងនិពន្ធដោយលោក ឱម ខែម*

---

*(១) ឱវាទ១០យ៉ាងរបស់ធនញ្ជ័យសេដ្ឋីដែលផ្ដាំចំពោះនាងវិសាខា នៅពេលដែលធ្វើដំណើរទៅនៅ ខាងស្វាមីនាង, ជាឱវាទទាក់ទងទៅនឹងចរិយារបស់ភរិយា, សូមនាំមកចុះជាគតិជូនព្រោះជារបស់ មានសារៈសំខាន់ហើយក៏ជាទីនិយមបំផុតនៃវប្បធម៌ និងអរិយធម៌ខ្មែរ។*

ដកស្រង់ចេញពី

***ទស្សនាវដ្ដីកម្ពុជសុរិយា,***

***ទស្សនាវដ្ដីផ្សព្វផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ***

*ឆ្នាំទី ៥៤ លេខ ២ ព.ស ២៥៤៤, គ.ស ២០០០*

ភិក្ខុ វណ្ណគុត្តោ ស្វាត សាលឿម